អង្គរបុរី

សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ ក្រោមប្រធានបទ លោកហេង-សំរិន ប្រធានរដ្ឋសភាខ្មែរ និយាយថា បញ្ហាព្រះសង្ឃខ្មែរកម្ពុជាក្រោម គឺជាកិច្ចការផ្ទៃក្នុងរបស់វៀតណាម មិនមែនជាកិច្ចការខ្មែរទេ ។

website : www.hoksavann.org

ថ្ងៃទី១៤ ឧសភា ២០០៧



លោកហេង-សំរិនពោលថា បញ្ហាព្រះសង្ឃខ្មែរកម្ពុជាក្រោម គឺជាកិច្ចការផ្ទៃក្នុងរបស់វៀតណាម ពុំមែនជារឿងរ៉ាវរបស់ខ្មែរទេ ។ ការពោលប្រាប់អ្នកសារព័ត៌មាននេះរប-ស់លោកហេង-សំរិន គឺនៅក្រោមពេលដែលសមាគមខ្មែរកម្ពុជាក្រោមនៅប្រទេសកម្ពុជា បានដាក់ពាក្យសុំឲ្យលោកហេង-សំរិនប្រធានរដ្ឋសភាខ្មែរ លើកយករឿងព្រះសង្ឃខ្មែរកម្ពុជាក្រោម មកពិភាក្សាជាមួយលោកង្វៀង-ភូជុងប្រធានរដ្ឋសភាវៀតណាម ដែលមកធ្វើទស្សនកិច្ចនៅកម្ពុជា នៅថ្ងៃទី២០មីនា២០០៧ ។ សំដីរបស់លោកហេង-សំរិន នេះជាការឆ្លុះបញ្ចាំងថា លោកហេង-សំរិនមិនទទួលស្គាល់ព្រះសង្ឃនិងជនជាតិខ្មែរ ដែលរស់នៅលើទឹកដីកម្ពុជាក្រោម ដែលពីដើមជាទឹកដីរបស់រាជាណាចក្រកម្ពុជា ដែលត្រូវបារាំងអាណានិគមកាត់ឲ្យវៀតណាម នៅថ្ងៃទី៤ មិថុនា ១៩៤៩ ថាជាព្រះសង្ឃនិងជាជនជាតិខ្មែរទេ ។ មួយទៀត លោកហេង-សំរិនបានដឹងអំពីសេចក្តីទុក្ខវេទនារបស់ព្រះសង្ឃ និងជនជាតិខ្មែរកម្ពុជាក្រោមដែរ ប៉ុន្តែមិនហ៊ានលើកឡើងធ្វើអន្តរាគមន៍ស្របតាមរដ្ឋធម្មនុញ្ញខ្មែរថា ខ្មែរនៅបរទេសមានទុក្ខត្រូវគាំពារ ដោយខ្លាចអំណាចវៀតណាម ដូច្នេះបញ្ជាក់ថា ប្រទេសកម្ពុជាពុំមានឯករាជ្យឡើយ គឺនៅក្រោមឥទ្ធិពលវៀតណាម ។ គួររំលឹកឡើងវិញថា នៅកម្ពុជាក្រោម ព្រះសង្ឃខ្មែរជាច្រើនអង្គបានត្រូវវៀតណាមចាប់ផ្សឹក រួចដាក់ពន្ធនាគារ ចំណែកនៅប្រទេសកម្ពុជាវិញ ចាប់ពីថ្ងៃ២៧ កុម្ភៈដល់ថ្ងៃ២៥មេសា២០០៧ ព្រះសង្ឃព្រះនាមអៀង-

សុខធឿន ត្រូវគេលួចធ្វើគត នៅមុនពេលព្រះសង្ឃខ្មែរកម្ពុជាក្រោមពិភពលោក ជាពិសេសព្រះសង្ឃខ្មែរក្រោមនៅភ្នំពេញ បានហែយកញ្ញត្តិទៅជូនឯកអគ្គរដ្ឋទូតវៀតណាមប្រចាំប្រទេសកម្ពុជា ទាមទារឲ្យវៀតណាមដោះលែងព្រះសង្ឃខ្មែរនៅកម្ពុជាក្រោម ដែលវៀតណាមបានចាប់ តែបានត្រូវក្រុមប៉ូលិសរារាំងរហូតមានអំពើហិង្សា ធ្វើឲ្យព្រះសង្ឃខ្លះត្រូវរបួស ។ ផ្ទុយទៅវិញ ក្រោយពេលដែលជនជាតិវៀតណាមបីនាក់ បានត្រូវបាញ់សម្លាប់នៅខេត្តពោធិសាត់ ក្នុងបញ្ហាច្របូកច្របល់មួយអំពីបញ្ហានេសាទត្រី អាជ្ញាធរវៀតណាមមានប្រតិកម្មយ៉ាងខ្លាំង អំពាវនាវឲ្យអាជ្ញាធរខ្មែរធ្វើការស៊ើបអង្កេតអំពីការសម្លាប់នេះ តើលោកហេង-សំរិនហ៊ានពោលថា នេះជាកិច្ចការផ្ទៃក្នុងរបស់ខ្មែរ មិនមែនជាកិច្ចការរបស់វៀតណាមទេ ដូចលោកបានពោលពីមុននេះថា បញ្ហាព្រះសង្ឃខ្មែរកម្ពុជាក្រោម គឺជាកិច្ចការផ្ទៃក្នុងរបស់វៀតណាម មិនមែនជាកិច្ចការរបស់ខ្មែរទេ ពិតជាលោកហេង-សំរិនមិនហ៊ានពោលដូច្នេះឡើយ ព្រោះកុំឲ្យមានទំនាស់ជាមួយវៀតណាម ។ ខ្មែរកម្ពុជាក្រោមអភ័ព្វណាស់ ពេលមានទុក្ខអាជ្ញាធរខ្មែរព្រងើយកន្តើយ បោះបង់ចោលមិនជួយដោះទុក្ខ ដែលមានលក្ខណៈផ្ទុយពីអាជ្ញាធរវៀតណាម គេយកចិត្តទុកដាក់ណាស់ នៅពេលដែលជនជាតិគេនៅបរទេសមានទុក្ខ ។

រាជរដ្ឋាភិបាលខ្មែរបានកំរិតសេរីភាពក្នុងការបញ្ចេញមតិ តាមរយៈការធ្វើកូដកម្ម បាតុកម្ម ដោយលើកយកមូលហេតុពុំសមហេតុពុំសមផលក្នុងការពុំអនុញ្ញាតនេះ ផ្ទុយពីប្រទេសប្រជាធិបតេយ្យដទៃទៀត គេអនុញ្ញាតរាល់ពេលសុំ ហើយរក្សាសន្តិសុខយ៉ាងល្អទៀតផង ។ សុំច្បាប់មិនឲ្យ ព្រះសង្ឃខ្មែរកម្ពុជាក្រោមសំរេចធ្វើ ត្រូវអាជ្ញាធរខ្មែរបង្ក្រាប ដូចព្រះសង្ឃខ្មែរកម្ពុជាក្រោមចំនួន៦០អង្គ បានធ្វើបាតុកម្ម ហែយកញ្ញត្តិ ទៅជូនឯកអគ្គរដ្ឋទូតវៀតណាមប្រចាំប្រទេសកម្ពុជា តែមិនបានសំរេច ដោយក្រុមប៉ូលិសខ្មែររាំងរយនាក់ទៅបង្ក្រាបដោយហឹង្សា រហូតព្រះសង្ឃ៦អង្គ បានត្រូវរបួស ។ ក្នុងការបង្ក្រាបដោយអំពើហឹង្សានេះ មានព្រះសង្ឃមួយក្រុមតូចទៀត ធ្វើការជួសឲ្យនគរបាល គឺមួយអង្គនាមសៅ-ច័ន្ទថុល ចៅអធិការវត្តលង្កា និងមួយអង្គទៀតនាមឡុង-គិមលាង អនុគណខណ្ឌដូនពេញ បានដឹកនាំព្រះសង្ឃប្អូនប្រាំអង្គទៀត មកបន្ទុចបង្អាក់ព្រះសង្ឃកម្ពុជាក្រោមត្រង់វត្តឧណ្ណាលោម ។ សកម្មភាពបែបនេះ យើងនឹកឃើញកាលពីមុន គេបង្ក្រាបបាតុកម្មដោយបង្កើតបាតុកម្មមួយក្រុមទៀតហៅថាសមាគមក្មេងវត្ត ឲ្យមកវាយប្រហារក្រុមបាតុកម្មពិតប្រាកដ ដូចពេលនេះ គេប្រើព្រះសង្ឃឲ្យវាយព្រះសង្ឃ ហើយប៉េអឹមនិងប៉ូលិសឈរមើល ហើយបន្ទុំចោលដុំថ្មត្រូវព្រះនេត្រព្រះសង្ឃកម្ពុជាក្រោមមួយអង្គចេញព្រះលោហិតជោគព្រះកាយ ។៚

❄